# សេចក្តីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា សុំឲ្យនាំខ្លួនមេខ្មែរក្រហមជាន់ខ្ពស់ ដាក់ក្នុងទីឃុំឃាំងម៉្លឹយមុនកាត់ទោស

**Website: www.hoksavann.org**

ថ្ងៃទី១១ កញ្ញា ២០០៤

ប្រជាពលរដ្ឋខ្មែរទូទៅនិងអង្គការសហប្រជាជាតិមានបំណងដូចគ្នា គឺត្រូវតែកាត់ទោសខ្មែរក្រហម ដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរដែលត្រូវខ្មែរក្រហមសម្លាប់អស់រាប់លាននាក់ ។ ប្រជាពលរដ្ឋខ្មែរដែលសល់ពីខ្មែរក្រហមសម្លាប់ ទទូចតាំងពីដំបូង សូមឲ្យគេប្រគល់រឿងកាត់ទោសនេះ ទៅអង្គការសហប្រជាជាតិដាច់មុខ ដោយសារការពុំទុកចិត្តតុលាការខ្មែរ ។ បំណងនេះចេញពុំរួច ដោយសារតែរដ្ឋាភិបាលខ្មែរបច្ចុប្បន្នមានសមាជិកខ្លះជាអតីតខ្មែរក្រហម និងអ្នកនៅពីក្រោយគឺវៀតណាមនិងចិនកុម្មុយនិស្ត តែងតែរារាំងកុំឲ្យអង្គការសហប្រជាជាតិបង្កើតតុលាការតែម្នាក់ឯង ។ សូម្បីតែរដ្ឋាភិបាលសំរេចបង្កើតតុលាការកាត់ទោសខ្មែរក្រហមរួមជាមួយអង្គការសហប្រជាជាតិហើយ បន្លាយពេលរហូតមកទល់ពេលនេះ ដោយសារតែរដ្ឋាភិបាលគ្មានសុឆន្ទៈពិតប្រាកដក្នុងការកាត់ទោសនេះ ។ កំហុសខ្មែរក្រហមជាទោសខុសច្បាប់អង្គការសហប្រជាជាតិ ដូច្នេះអង្គការនេះមានមុខងារចាំបាច់ក្នុងការកាត់ទោសនេះ ពុំមែនដូចរដ្ឋាភិបាលខ្មែរថា បើអង្គការសហប្រជាជាតិបង្កើតតុលាការតែម្នាក់ឯង ជាការរំលោភលើអធិបតេយ្យភាពខ្មែរនោះឡើយ ។ ឥឡូវនេះតាមការព្រមព្រៀងគ្នា ភាគីខាងខ្មែរមានចៅក្រមមេធាវីច្រើនជាងភាគីខាងអង្គការសហប្រជាជាតិ ត្រង់ចំណុចនេះហើយ ដែលប្រជាពលរដ្ឋខ្មែរនៅតែមានសេចក្តីសង្ស័យថា ក្រែងតុលាការចំរុះនេះពុំអាចរកយុត្តិធម៌ជូនអ្នករងគ្រោះបាន ដោយការពុំទុកចិត្តចៅក្រមមេធាវីខ្មែរ ពុំឯករាជ្យមានឥទ្ធិពលពីអ្នកកាន់អំណាចខ្មែរ និងអ្នកពាក់ព័ន្ធពីក្រោយ គឺចិនកុម្មុយនិស្តនិងវៀតណាម ។ ខ្មែរក្រហមដែលត្រូវកាត់ទោសនោះ គឺមេខ្មែរក្រហមជាន់ខ្ពស់ ដែលមានឯកសារពាក់ព័ន្ធនឹងការកាប់សម្លាប់នេះ បើតាមពត៌មាននៃការព្រមព្រៀងគ្នារវាងភាគីទាំងពីរ កម្ពុជានិងអង្គការសហប្រជាជាតិ ។ សព្វថ្ងៃមេខ្មែរក្រហមទាំងនោះ កំពុងមានសេរីភាពដើរទៅណាក៏បាន វៀរលែងតែខ្មែរក្រហមពីរនាក់ ដែលកំពុងជាប់ឃុំ ។

ចម្លើយទៅនឹងសំនួរថា ព្រះពុទ្ធបានប្រៀនប្រដៅមិនឲ្យមនុស្សចងពៀរនឹងគ្នា ដោយព្រះពុទ្ធដីកាថា ពៀរពុំអាចរំងាប់ដោយការចងពៀរឡើយ តែពៀរអាចរំងាប់ដោយការមិនចងពៀរ ។ ចុះបើពុទ្ធសាសនិកជនខ្មែរ រួមទាំងព្រះសង្ឃផង ចង់ឲ្យគេកាត់ទោសខ្មែរក្រហម តើស្របតាមពុទ្ធភាសិតនេះឬទេ ? ពាក្យថាពៀររំងាប់ដោយការមិនចងពៀរ មានន័យថា អ្នកធ្វើអំពើអាក្រក់មកលើខ្លួន មិនធ្វើអាក្រក់តបវិញ ដែលជាលក្ខណៈជនសប្បុរស មានព្រះទ័យបរិសុទ្ធ ដោយឈ្នះសេចក្តីអាក្រក់ក្នុងព្រះទ័យរបស់លោក ។ បានសេចក្តីថា លោកអ្នកសប្បុរសពុំញ៉ាំងអំពើបាបណាមួយឲ្យកើតឡើង ដោយសារអ្នកដទៃបៀតបៀនឡើយ ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មិនឲ្យប្រើធម៌ហឹង្សាតបទៅមនុស្សដែលបៀតបៀនខ្លួន ប៉ុន្តែព្រះអង្គណែនាំឲ្យរកវិធីការពារ កុំឲ្យជនពាលដែលប្រព្រឹត្តអាក្រក់នោះបៀតបៀនខ្លួនតទៅទៀត ដោយវិធីផ្សេងៗ មានហាមកុំឲ្យសេពគប់ជនពាល បើមានជនពាលកន្លែងណា ត្រូវចៀសវាងឲ្យឆ្ងាយ និងមួយទៀត ត្រូវប្រាប់អ្នកកាន់អំណាចរដ្ឋឲ្យជួយដោះស្រាយតាមក្របខ័ណ្ឌច្បាប់របស់រដ្ឋ ។ គ្រប់ប្រទេសទាំងអស់ជាពិសេសប្រទេសកម្ពុជាតែងតែមានច្បាប់សំរាប់រដ្ឋ និងច្បាប់អង្គការសហប្រជាជាតិសំរាប់ពិភពលោក ។ ចំពោះប្រទេសកម្ពុជា ព្រះសង្ឃនិងគ្រហស្ថជាជនជាតិកម្ពុជារដ្ឋត្រូវរក្សាការពារ ដោយឃាត់ឃាំងរាំងរាមិនឲ្យជនណាមួយរំលោភលើជនណាមួយឡើយ ។ ការប្រាប់អ្នកកាន់អំណាចរដ្ឋឲ្យជួយការពារនេះ ពុំឈ្មោះថាចងពៀរឡើយ ព្រោះការធ្វើទោសឬពុំធ្វើទោសចំពោះអ្នកប្រព្រឹត្តអាក្រក់នោះ គឺស្ថិតនៅលើច្បាប់របស់រដ្ឋ ឬច្បាប់អង្គការសហប្រជាជាតិ ពុំមែនអ្នករងគ្រោះនោះវិនិច្ឆ័យខ្លួនឯងឡើយ ។ ចំពោះការយល់ស្របឲ្យកាត់ទោសខ្មែរក្រហម ដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរ ស្របនឹងន័យខាងលើនេះ ព្រោះអំពើរបស់ខ្មែរក្រហម ទាក់ទងនឹងច្បាប់របស់ជាតិនិងច្បាប់អន្តរជាតិ ពុំឈ្មោះថាចងពៀរជាមួយខ្មែរក្រហមឡើយ ។ មនុស្សទាំងអស់ក្នុងសង្គមកម្ពុជា ត្រូវស្ថិតនៅក្រោមអំណាចច្បាប់របស់ជាតិនិងច្បាប់អន្តរជាតិ ។ បើគ្មានច្បាប់ឬមានច្បាប់ហើយពុំអនុវត្តតាម នោះអ្នកដែលរំលោភលើច្បាប់ នៅតែរំលោភ ហើយអ្នកដែលទទួលរងគ្រោះនៅតែទទួលរងគ្រោះ ដូច្នេះត្រូវតែមានតុលាការឯករាជ្យមួយ រកយុត្តិធម៌ជូនអ្នករងគ្រោះ ។ បើអ្នកនោះមានទោស គឺច្បាប់ជាអ្នកដាក់ទោស ពុំមែនអ្នករងគ្រោះដាក់ទោសឡើយ ។ ដូចព្រះភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ដែលបានបួសហើយត្រូវស្ថិតនៅក្រោមអំណាចព្រះវិន័យ ដែលព្រះពុទ្ធបានបញ្ញត្តិ ។ បើភិក្ខុអង្គណាមួយប្រព្រឹត្តខុសវិន័យ ព្រះវិន័យធរត្រូវធ្វើតាមទោសធ្ងន់ស្រាល ដែលភិក្ខុនោះបានប្រព្រឹត្ត ។ ដូច្នេះព្រះវិន័យធរកាត់សេចក្តីតាមកំហុស ដែលភិក្ខុសង្ឃនោះបានប្រព្រឹត្តខុស ពុំមែនបានន័យថា វិន័យធរនោះចងពៀរនឹងភិក្ខុនោះឡើយ គឺអនុវត្តតាមតែព្រះវិន័យដែលព្រះពុទ្ធបានបញ្ញត្តិមកតែប៉ុណ្ណោះ ហើយដែលភិក្ខុអង្គនោះសុខចិត្តអនុវត្តតាមពេលដែលមកបួស ។ មួយទៀតមានបញ្ញត្តិថា បើភិក្ខុអង្គណាមួយ ឃើញភិក្ខុផ្សេងទៀតប្រព្រឹត្តខុស ត្រូវប្រាប់វិន័យធរ ។ ការប្រាប់នេះពុំមែនបានន័យថា ភិក្ខុសង្ឃនោះចងពៀរនឹងភិក្ខុប្រព្រឹត្តខុសនោះឡើយ តែប្រាប់បំណងឲ្យភិក្ខុនោះធ្វើកិច្ចតាមព្រះវិន័យ ដើម្បីឲ្យរួចចាកអាបត្តិ និងស្ថិតនៅក្នុងសេចក្តីបរិសុទ្ធវិញ ។ មានរឿងរ៉ាវជាច្រើនក្នុងពុទ្ធសាសនា មានការទាស់ទែងខ្វែងគំនិតគ្នាជាដើមរបស់ភិក្ខុសង្ឃបានត្រូវព្រះពុទ្ធរម្ងាប់អធិករណ៍ទាំងនោះ ដោយយកព្រះវិន័យជាគោល ។ ដូច្នេះសរុបសេចក្តីមក ព្រះភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ត្រូវស្ថិតនៅក្រោមអំណាចច្បាប់ព្រះវិន័យ ដែលព្រះពុទ្ធបានបញ្ញត្តិមក ។ ចំណែកផ្លូវអាណាចក្រ ត្រូវស្ថិតនៅក្រោមអំណាចច្បាប់របស់ជាតិនិងច្បាប់អន្តរជាតិ ដែលមនុស្សក្នុងប្រទេសនីមួយៗ និងមនុស្សនៅក្នុងសកលលោកនាំគ្នាតាក់តែងឡើង ។ ដូចនេះ ការកាត់ទោសព្រះភិក្ខុសង្ឃ ដែលប្រព្រឹត្តខុសព្រះវិន័យ ដូចគ្នានឹងការយល់ស្របឲ្យកាត់ទោសខ្មែរក្រហម តាមច្បាប់ជាតិនិងច្បាប់អន្តរជាតិ ពុំឈ្មោះថាចងពៀរខ្មែរក្រហមឡើយ ។

ពេលវេលានៃការកាត់ទោសខ្មែរក្រហមនេះ ពុំដឹងជាត្រូវកើតឡើងនៅវេលាណាទេ មួយទៀតមេខ្មែរក្រហមជាន់ខ្ពស់ទាំងនោះ មានវ័យចាស់ជរា ហើយមានជម្ងឺផង មិនដឹងជារស់នៅបានរហូតដល់ពេលកាត់ទោសឬយ៉ាងណាទេ ។ នេះជាបញ្ហាមួយ បញ្ហាមួយទៀតគេបារម្ភថា ជិតពេ

លកាត់ទោស ស្រាប់តែមេខ្មែរក្រហមទាំងនោះរត់បាត់ ឬត្រូវស្លាប់មិនប្រក្រតី ។ ដោយការបារម្ភនេះហើយ បានជាពេលនេះ សូមអំពាវនាវចំពោះក្រសួងមានសមត្ថកិច្ច សូមនាំខ្លួនមេខ្មែរក្រហមជាន់ខ្ពស់ ដាក់ក្នុងទីឃុំឃាំងមួយមុនកាត់ទោស ដើម្បីការពារសន្តិសុខជូនខ្មែរក្រហមទាំងនោះផង និងដើម្បីកុំឲ្យខ្មែរក្រហមទាំងនោះរត់គេចខ្លួន ឬត្រូវស្លាប់ពុំប្រក្រតីដូចការស្លាប់របស់ប៉ុល-ពត ព្រោះបណ្ដាខ្មែរក្រហមនេះមានការពាក់ព័ន្ធទៅលើប្រទេសចិនកុម្មុយនិស្តនិងប្រទេសវៀតណាម ដែលធ្លាប់គាំទ្រខ្មែរប្រហមពីដើមមក ។

មតិទូទៅមានការសង្ស័យថា ការស្លាប់របស់ប៉ុល-ពតជាការស្លាប់ពុំប្រក្រតី ជាការស្លាប់ដោយហេតុផលនយោបាយ ព្រោះមានហេតុផលពីរយ៉ាងជាប្រវត្តិសាស្ត្រ គួរលើកយកមកពិចារណាដូតទៅនេះ ៖

ហេតុផលទី១ ៖ ក្រោយពេលលោក Bill Clinton ប្រធានាធិបតីនៃសហរដ្ឋអាមេរិក បានបញ្ជាទៅក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ និងក្រសួងការបរទេស ឲ្យរៀបចំធ្វើគំរោងការចាប់ប៉ុល-ពតកាត់ទោសនៅតុលាការអន្តរជាតិ ។ ជាមួយគ្នានោះ លោកប្រធានាធិបតីបានទាក់ទងក្រសួងការបរទេសចិនប្រជាមានិតុ សួរយោបល់អំពីការកាត់ទោសប៉ុល-ពតនេះ ។ ចិនមិនទាន់បានឆ្លើយតបផង ស្រាប់តែឬថាប៉ុល-ពតត្រូវស្លាប់ ។ គេមានការសង្ស័យថា ជាយូរឆ្នាំមកហើយ ជាពិសេសមុនសំណើលោក Clinton ម៉េចក៏ប៉ុល-ពតមិនស្លាប់ គឺគាត់ត្រូវស្លាប់ដោយក្រុមណាមួយ ដើម្បីបំបិទមាត់កុំឲ្យឆ្លើយក្នុងតុលាការអន្តរជាតិ ។ គួរបញ្ជាក់ឡើងវិញ ចិនកុម្មុយនិស្តនេះហើយដែលគាំទ្រខ្មែរក្រហមគ្រប់បែបយ៉ាង ។ នៅពេលខ្មែរក្រហមឡើងកាន់អំណាច ក៏ចិនប្រជាមានិតុបញ្ជូនទីប្រឹក្សានិងបច្ចេកទេសចិនទៅប្រទេសខ្មែរ ជាពិសេសក្នុងរយៈពេលកាប់សម្លាប់ ។

ហេតុផលទី២ ៖ នៅពេលជាមួយគ្នានោះ រដ្ឋាភិបាលភ្នំពេញក៏បានលើកទ័ពទៅតាមចាប់ប៉ុល-ពតដែរ រុករករហូតចូលដល់អន្លង់វែង ឃើញផ្ទះតាម៉ុកទៀតផង ។ មិនតែប៉ុណ្ណោះ បានចាត់គណៈប្រតិភូឲ្យទៅប្រទេសថៃ ដើម្បីទៅជួបបុរសដៃស្ដាំម្នាក់របស់ប៉ុល-ពត ដែលបែកចេញពីប៉ុល-ពត ។ តើគណៈប្រតិភូបានជួបនិយាយអាថ៌កំបាំងដូចម្ដេចខ្លះ ដើម្បីតាមចាប់ឬកំទេចប៉ុល-ពត ។ តើប៉ុល-ពតស្លាប់នៅទីណា មុននឹងយកសពមកទុកក្នុងលំនៅគាត់វិញ ព្រោះប៉ុល-ពតតែងតែចោទជាញឹកញាប់ចំពោះវៀតណាមនិងបក្សប្រជាជនដែលជាអតីតខ្មែរក្រហមថា ជាអ្នកសម្លាប់ខ្មែរ ចូលមកឈ្លានពានចង់យកប្រទេសខ្មែរ ធ្វើជាអាណានិគមនិយមដូចជាប្រទេសលាវ ។

ហេតុផលទាំងពីរយ៉ាងនេះហើយ ដែលសង្ស័យថា ការស្លាប់របស់ប៉ុល-ពតមានហេតុផលនយោបាយ ដោយបំបាត់ជីវិតគាត់ មុនចាប់គាត់ឡើងឆ្លើយក្នុងតុលាការអន្តរជាតិ ព្រោះគាត់ដឹងរឿងពិតជាងមេខ្មែរក្រហមណាទាំងអស់ បើទុកឲ្យគាត់ឆ្លើយ ពិតជាពាក់ព័ន្ធទៅលើគេ ដែលនាំឲ្យខ្មែរស្លាប់រាប់លាននាក់ ។ ដោយហេតុនេះហើយបានជា សុំអំពាវនាវឲ្យនាំមេខ្មែរក្រហមជាន់ខ្ពស់មកឃាំងទុកក្នុងទីមួយដ៏សមរម្យ មុនតុលាការកាត់ទោសកើតឡើង ដើម្បីជៀសវាងការស្លាប់ពុំប្រក្រតីនេះឯង ។៚